ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០០៦/១៥ សពក.ពាណ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៥

ថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៥ វេលាម៉ោង ៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងះ

**១- សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥**

**២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើតការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក**

**៣- បញ្ហាផ្សេងៗ**

### ១-សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គឺឈរលើទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ ២០៣០ ពិសេស *«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣»*។ រាជរដ្ឋាភិបាលបានចង្អុលឲ្យរៀបចំ និងដាក់ចេញនូវគោលនយោបាយនេះ ដើម្បីជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្នតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ម្យ៉ាងទៀតការរៀបចំ និងការដាក់ចេញនូវគោលនយោបាយនេះឡើង បញ្ជាក់អំពីភាពចាំបាច់ និងបន្ទាន់ក្នុងការបង្កើតនូវ *យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី* ដើម្បីឆ្លើយតបនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធ ឧស្សាហកម្មកម្ពុជាពី *ឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹម ឆ្នាំ២០២៥* តាមរយៈការតភ្ជាប់ទៅនឹងខ្សែចង្វាក់តម្លៃសកល, សមាហរណកម្មទៅក្នុង បណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និង ស-

ការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។

ដើម្បីសម្រេចចក្ខុវិស័យខាងលើ *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»* កំណត់ដាក់ចេញនូវគោលដៅចំនួនបី៖ ទី១-បង្កើនចំណែកវិស័យឧស្សាហកម្មក្នុងកំណើនសេដ្ឋកិច្ច ក្នុងស្រុកសរុប (ផសស) ឲ្យបាន ៣០% នៅឆ្នាំ២០២៥ តាមតម្លៃបច្ចុប្បន្ន (កើនពី ២៤,១%នៃផសស នៅឆ្នាំ២០១៣) ដែលវិស័យកម្មន្តសាលត្រូវកើនឡើងពី ១៥,៥% នៃ ផសស នៅឆ្នាំ ២០១៣ ទៅដល់ ២០% នៅឆ្នាំ ២០២៥, ទី២- ជំរុញពិពិធកម្មមុខទំនិញដោយបង្កើនការនាំចេញទំនិញកម្មន្តសាលមិនមែនជាវាយនភ័ណ្ឌឲ្យមានចំណែក ១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ ទន្ទឹមនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឲ្យមានចំណែក ១២% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០២៥, និងទី៣- កំណត់គោលដៅនៅឆ្នាំ ២០២៥ ឲ្យសហគ្រាសធុនតូចចំនួន ៨០% និងសហគ្រាសមធ្យមចំនួន ៩៥% ត្រូវបានចុះបញ្ជីជាផ្លូវការហើយសហគ្រាសធុនតូចចំនួន ៥០% និងសហគ្រាសមធ្យមចំនួន ៧០% មានបញ្ជិការគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ។

បន្ថែមលើវិធានការ និងផែនការសកម្មភាព ដូចមានចែងក្នុងគោលនយោបាយនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **វិធានការជាក់ស្តែងគន្លឹះបួនយ៉ាង** ឲ្យសម្រេចបាន នៅមុនដំណាច់ឆ្នាំ ២០១៨ ដែលជាបង្គោលចរដ៏សំខាន់សម្រាប់វាស់វែងកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពក្នុងការអនុវត្ត *«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»* ព្រមទាំង ជាមូលដ្ឋាន និងជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន សម្រាប់អនុវត្តនូវចក្ខុវិស័យ គោលបំណង និងគោលដៅ នៃគោលនយោបាយនេះ ឲ្យទទួលបានជោគជ័យ។ វិធានការទាំងនេះ រួមមាន៖ ទី១-បញ្ចុះថ្លៃផ្គត់ផ្គង់អគ្គិសនីសម្រាប់តំបន់ឧស្សាហកម្មគោលដៅ រួមទាំង ពង្រីកវិសាលភាព គ្របដណ្តប់ និងលើកកម្ពស់ភាពទុកចិត្តក្នុងការផ្គត់ផ្គង់ចរន្ត, ទី២-រៀបចំ និងអនុវត្តផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកពហុមធ្យោបាយ, ទី៣- ពង្រឹង និងអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ និងទី៤- អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។

## ២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក

ការរីកចំរើនសេដ្ឋកិច្ចដ៏ល្អប្រសើរ ក្នុងរយៈពេលជាងដប់ឆ្នាំកន្លងមកនេះតាមរយៈនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី១ ទី២ និងតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការនាំអង្ករចេញឲ្យបាន ១លានតោន ក្នុងឆ្នាំ២០១៥ បានធ្វើឲ្យការអភិវឌ្ឍវិស័យធនធានទឹកមានការរីកចំរើនឡើងទ្វេដង ជាពិសេសកំណើនផ្ទៃដីស្រោចស្រពមានការកើនឡើងខ្ពស់គួរឲ្យកត់សំគាល់ (គិតមកដល់ចុងឆ្នាំ ២០១៣ ប្រព័ន្ធស្រោចស្រពមានសក្តានុពលស្រោចស្រពរហូតដល់ជិត ១លាន ៥សែនហិកតា)។

ក្នុងគោលបំណងធានាបាននូវសមិទ្ធផល ដែលជាទ្រព្យសម្បត្តិនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលរាជរដ្ឋាភិបាលរួមជាមួយដៃគូបានវិនិយោគ និងកាត់បន្ថយបាននូវការចំណាយ ៩០/

ចរិកាជាតិដ៏ច្រើនលើការថែទាំប្រព័ន្ធធារាសាស្ត្រ រាជរដ្ឋាភិបាលដែលមានក្រសួងធនធានទឹក និងឧតុនិយម បានរួមជាមួយដៃគូអភិវឌ្ឍន៍កន្លងមក បានដាក់ចេញនូវគោលនយោបាយនូវការចែករំលែកនៃការថែទាំប្រព័ន្ធធារាសាស្ត្រ រវាងសហគមន៍កសិករប្រើប្រាស់ទឹក និងក្រសួងធនធានទឹក និងឧតុនិយម ដោយយោងតាមស្មារតីសារាចរលេខ០១ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងប្រព័ន្ធស្រោចស្រពប្រកបដោយនិរន្តភាព ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ១៩៩៩ និងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅកម្ពុជាដែលបានដាក់ឲ្យអនុវត្តន៍នាឆ្នាំ ២០០៧។

អនុក្រឹត្យនេះមានគោលបំណងធានាបាននូវការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះមានគោលដៅកំណត់ពីនីតិវិធីនៃការបង្កើត ការរំលាយចោល ហើយនិងតួនាទីនិងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹកនៅព្រះរាជាណាចក្រកម្ពុជា។ សហគមន៍កសិករប្រើប្រាស់ទឹកសរសេរជាអក្សរកាត់ថា **ស.ក.ប.ទ**។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ **ស.ក.ប.ទ** ទាំងអស់ ដែលប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទីនិងភារកិច្ចនៃសហគមន៍ កសិករប្រើប្រាស់ទឹកនេះមាន ១២ជំពូក និង ៤២មាត្រា។

ដោយសារសេចក្តីព្រាងអនុក្រឹត្យនេះ បានដាក់ឆ្លងអង្គប្រជុំកម្រិតបច្ចេកទេស កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយជាច្រើនដង **សម្តេចអគ្គមហាសេនាបតីតេជោ** បានណែនាំឲ្យក្រសួងធនធានទឹក និងឧតុនិយម យកទៅពិនិត្យ ផ្ទៀងផ្ទាត់ជាចុងក្រោយ មុននឹងដាក់ឲ្យអនុវត្តដោយរាជរដ្ឋាភិបាល។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១២ និង ៣០ នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៥